# កម្ពុជា ៖ តើរដ្ឋធម្មនុញ្ញ បានបញ្ញត្តិយ៉ាងណាខ្លះ អំពី ព្រះមហាក្សត្រ និង អំណាច របស់ព្រះអង្គ ?

*ដោយ* **ទិត ហួន**
បណ្ឌិតច្បាប់

ជាដំបូង ក្នុងព្រះឋានៈព្រះអង្គជា"**និមិត្តរូប នៃឯកភាពជាតិ និង និរន្តរភាពជាតិ**"(មាត្រា៨ វគ្គទី១) "**ព្រះមហាក្សត្រ មានតួនាទីខ្ពង់ខ្ពស់ ជាអាជ្ញាកណ្តាល ដើម្បីធានា ការប្រព្រឹត្តទៅ នៃអំណាចសាធារណៈ ឲ្យមានភាពទៀងទាត់**" (មាត្រាទី៩)" ។ ដោយឡែកទៀត "**ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិ បន្ធូរ-បន្ថយទោស និងលើកលែងទោស** " (មាត្រា២៧)។

បន្ទាប់មក រដ្ឋធម្មនុញ្ញបានថ្វាយ ចំពោះព្រះមហាក្សត្រ នូវព្រះបន្ទុក "**ជាអ្នកធានា ឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា**" និងជា"**អ្នកធានា ការគោរពសន្ធិសញ្ញា អន្តរជាតិ**" (មាត្រា៨ វគ្គ២)។ មួយចំណែកទៀត "**ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ថលេខា លើសន្ធិ-សញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័ន លើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយទទួលបាន ការ អនុម័តយល់ព្រម ពីរដ្ឋសភា និងព្រឹទ្ធសភា**" (មាត្រា២៦ថ្មី)។ ម្យ៉ាងទៀត "**ព្រះមហាក្សត្រ ទ្រង់ជាមេ បញ្ជាការកំពូល នៃកងយោធពលខេមរៈភូមិន្ទ**" (មាត្រា២៣) និង "**ទ្រង់ជាព្រះអធិបតី នៃឧត្តមក្រុម-ប្រឹក្សាការពារជាតិ**"(មាត្រា២៤ វគ្គ១)។

រួច ជាចុងក្រោយ រដ្ឋធម្មនុញ្ញបានថ្វាយ ចំពោះព្រះមហាក្សត្រ នូវតួនាទីដ៏ខ្ពង់ខ្ពស់ជា "**អ្នកធានា ការគោរពសិទ្ធិនិងសេរីភាព របស់ប្រជាពលរដ្ឋ**" (មាត្រា៨ វគ្គ២) និងជា "**អ្នកធានាឯករាជ្យ នៃអំណាច តុលាការ** (មាត្រា១៣២ថ្មី)។ ដោយហេតុនេះហើយ ទើប**ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ស្ថិតនៅក្រោម ព្រះរាជអធិបតីភាព នៃព្រះមហាក្សត្រ** (មាត្រា១៣៤ថ្មី វគ្គ២)។

ដូចនេះ ដូចដែលយើងសង្កេតឃើញខាងលើ រដ្ឋធម្មនុញ្ញ ទោះបីបានចែង នូវមាត្រា៧ ថា "**ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ**" ក៏ដោយ ក៏បានថ្វាយចំពោះ ព្រះមហាក្សត្រ នូវអំណាចសំខាន់ៗ ក្នុងវិស័យចំបងៗមួយចំនួន នៃជីវិតនយោបាយជាតិ។ បើនិយាយ ស្រួលស្តាប់ ព្រះមហាក្សត្រទ្រង់មាន ៖

១/- **អំណាចផ្ទាល់**របស់ព្រះអង្គ គឺអំណាចក្នុងនាមទ្រង់ ជាក្នុងតួនាទី ជាអជ្ញាកណ្តាល និង ព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស។

២/- **អំណាចរួមចែកគ្នា** យ៉ាងទូលំទូលាយ ក្នុងវិស័យ ៖

ក/- ទំនាក់ទំនងអន្តរជាតិ និងការពារជាតិ រួមចែកគ្នា ជាមួយនឹងរាជរដ្ឋាភិបាល និងសភា ទាំង២។

ខ/- ការពារសិទ្ធិនិងសេរីភាព របស់ប្រជាពលរដ្ឋ ចែកគ្នាជាមួយ នឹងអំណាចតុលាការ អំណាចនិតិបញ្ញត្តិ និងអំណាចនិតិប្រតិបត្តិ។

រដ្ឋធម្មនុញ្ញ បានថ្វាយចំពោះព្រះមហាក្សត្រ ក្នុងនាមជាស្ថាប័នរបស់រដ្ឋ នូវថ្នាក់ទី១ ដោយបានចែងបទបញ្ញត្តិ ស្តីពីព្រះអង្គ ក្នុងជំពូកទី២ បន្ទាប់ពីជំពូកទី១ ស្តីពីអធិបតេយ្យ។ ការដាក់បង្ហាញឲ្យខ្ពស់លើសគេដូចនេះ មានន័យថា រដ្ឋធម្មនុញ្ញ ទទួលស្គាល់ព្រះមហាក្សត្រ ជាស្ថាប័នកំពូលខ្ពង់ខ្ពស់ លើសស្ថាប័នដទៃទៀតរបស់រដ្ឋ។

ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញយើង ច្បាស់ជាបានតាក់តែងឡើង ដោយយកលំនាំ តាមរដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៩៥៨។ ហេតុដូចនេះហើយ បានជាមាត្រាទាំងឡាយ ដែលថ្វាយអំណាច ដល់ព្រះមហាក្សត្រ នៅប្រទេសកម្ពុជាយើង (មាត្រា៨ និងមាត្រា៩ ជាដើម) ដូចគ្នានឹងការជូនអំណាច ដល់ប្រធានាធិបតីបារាំង (នៃមាត្រាទី៥ ជាពិសេស) ត្រូវបានតាក់តែងឡើង ដោយប្រើពាក្យពេចន៍ ប្រហាក់ប្រហែលគ្នា (១)។

ដោយផ្អែកលើបទបញ្ញត្តិ នៃមាត្រាទី៥ របស់រដ្ឋធម្មនុញ្ញបារាំង ឆ្នាំ១៩៥៨ នេះហើយ ទើបប្រធានាធិបតីបន្តបន្ទាប់គ្នា នៃសាធារណរដ្ឋបារាំងទី៥ បានគោងទាម យកការដឹកនាំ កិច្ចការបរទេស និងការពារជាតិ របស់រដ្ឋបារាំង ថាជាតួនាទីផ្តាច់មុខ របស់ខ្លួន បើប្រដូចទៅ នឹងអំណាច របស់រដ្ឋមន្ត្រីទី១ របស់ខ្លួន។ ប្រធានាធិបតីទី១ នៃសាធារណរដ្ឋបារាំងទី៥ លោក ឧត្តមសេនីយ៍ ដឺហ្គោល (De Gaulle) បានទាមទារយកមុខនាទី មានប្រៀបលើគេនេះ មុនពេលដែលគាត់ត្រូវបានជ្រើសតាំង តាមវិធីបោះឆ្នោតជាសាកល ម្ល៉េះ។

ដូចនេះ យើងអាចសន្និដ្ឋានបាន ថា ជាការផ្ទុយនឹងសេចក្តីយុត្តធម៌ ប្រសិនបើមានការអះអាង ថាបទបញ្ញត្តិធម្មនុញ្ញ ដូចគ្នាបេះបិទ ប្រែជាមានន័យ តាមផ្លូវច្បាប់ ខុសគ្នា នៅពេលដែលគេយកមកអនុវត្តនៅកម្ពុជា។

ជាការពិតណាស់ហើយថា ប្រធានាធិបតីបារាំង ជាអធិបតីផង និងកាន់អំណាចផង នៅប្រទេសលោក ក៏ប៉ុន្តែព្រះមហាក្សត្រ "ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ"។ ភាពខុសគ្នានេះបណ្តាលមកពីប្រធានាធិបតីបារាំង លោកមានអំណាចគ្រប់វិស័យទាំងអស់ ក្នុងជីវិតនយោបាយជាតិគេដូចគ្នានិងរដ្ឋមន្ត្រីទី១ របស់លោក។ ចំណែកឯព្រះមហាក្សត្រកម្ពុជា ព្រះអង្គទ្រង់មានអំណាច តែក្នុងវិស័យ ដែលរដ្ឋធម្មនុញ្ញខ្មែរ បានរ៉ាយរ៉ាប់ ថ្វាយព្រះអង្គ។

គួរយើងរំឭកឡើងវិញថា ច្បាប់កំពូលរបស់កម្ពុជាយើង ដែលបានថ្វាយចំពោះព្រះមហាក្សត្រ នូវអំណាចទាំងឡាយ ដែលយើងបានរៀបរាប់ខាងលើ ត្រូវបានតាក់តែងឡើង ដោយសភាធម្មនុញ្ញ ដែលប្រជាជនខ្មែរ ប្រកបដោយអធិបតេយ្យភាព បានជ្រើសតាំងឡើង កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩១ ហើយដែលបានចូលកាន់តំណែង ជាផ្លូវការ នៅភ្នំពេញ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំដដែល។ ហើយគួរ

កុំភ្លេចថា គឺសភាធម្មនុញ្ញដដែលនេះហើយ ដែលបានតាំងបង្កើត ព្រះរាជាណាចក្រទី២។ លើសពីនេះទៅទៀត ក្នុងចំណោមសមាជិក៩រូប នៃឧត្តមក្រុមប្រឹក្សារាជសម្បត្តិ (មាត្រាទី១៣) ដែលជ្រើសរើសព្រះមហាក្សត្រ មានសមាជិក ៧រូប ជាតំណាងផ្ទាល់ ឬដោយប្រយោល របស់ប្រជាជនខ្មែរ។

ដូចនេះ ព្រះមហាក្សត្រ ក៏ដូចជារដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលដែរ ព្រះអង្គគឺជាព្រះរាជ-តំណាង របស់ប្រជាជនខ្មែរមួយដែរ ហើយដូចគ្នានឹងស្ថាប័នជាតិទាំងនោះដែរ ព្រះអង្គទ្រង់បានទទួលភាពពេញច្បាប់ និងអំណាច ពីប្រជាជនខ្មែរទាំងមូលដែរ។ អាស្រ័យហេតុនេះ ដូចគ្នានឹងសភាទាំង២ និងរាជរដ្ឋាភិបាល ព្រះមហាក្សត្រ អាចប្រើអំណាចរបស់ព្រះអង្គ ដូចដែលព្រះអង្គយល់ឃើញ ឲ្យតែព្រះអង្គទ្រង់ការពារ ផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់ របស់ជាតិយើង ហើយនិងទ្រង់គោរព លិខិតបទដ្ឋាន និងបទបញ្ញត្តិច្បាប់ និង រដ្ឋធម្មនុញ្ញ ដែលនៅជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

អំណាចទាំង៣ មុននឹងចាត់វិធានការអ្វីមួយ ក្នុងវិស័យ ដែលព្រះមហាក្សត្រទ្រង់មានអំណាច គេត្រូវតែស្នើសូមព្រះយោបល់ របស់ព្រះអង្គ ហើយគេត្រូវតែគោរព តាមព្រះយោបល់នេះ ហើយ ដោយហេតុថា ព្រះមហាក្សត្រ ទ្រង់ជាស្ថាប័នកំពូល របស់កម្ពុជា អំណាចរបស់ព្រះអង្គ ត្រូវតែមានប្រៀប ជាងអំណាចដទៃទៀត។

អ្នកខ្លះយល់ច្រឡំថា ក្នុងរដ្ឋធម្មនុញ្ញខ្មែរយើង មានការផ្ទុយគ្នា រវាងមាត្រាទី៧ ដែលចែងថា "ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ" ហើយនិងមាត្រាដទៃៗទៀត ដែលថ្វាយអំណាច ចំពោះព្រះមហាក្សត្រ ដូចដែលយើងបានរៀបរាប់ខាងលើ។ អ្នកខ្លះទៀត ក៏យល់ច្រឡំថា មាត្រាទី៧នេះ មានប្រៀបលើមាត្រាដទៃទៀត ស្តីពីព្រះមហាក្សត្រ។

ការពិត ក្នុងរដ្ឋធម្មនុញ្ញយើង គ្មានការផ្ទុយគ្នា រវាងមាត្រាទី៧ និងមាត្រាដទៃទៀតទេ ហើយក៏គ្មានមាត្រាណាមួយ មានប្រៀប មានតម្លៃ លើសមាត្រាដទៃទៀតឡើយ។

ជាការពិតណាស់ហើយ ព្រះមហាក្សត្រ ទ្រង់មិនកាន់អំណាចឡើយ ពីព្រោះព្រះអង្គ ទ្រង់មិនមែនជាអ្នកដឹកនាំ អំណាចនិតិប្រតិបត្តិទេ តែព្រះអង្គទ្រង់មានអំណាចផ្ទាល់ របស់ព្រះអង្គ និងអំណាចមួយចំនួនទៀត រួមចែកជាមួយស្ថាប័នដទៃទៀត របស់ព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុ ដែលបានពន្យល់មកខាងលើ ក្នុងវិស័យកិច្ចការទាក់ទងអន្តរជាតិ និង ការពារជាតិ ព្រះអង្គទ្រង់បានទទួលសហការ ជាមួយសភាទាំង២ និងរាជរដ្ឋាភិបាល ហើយ ក្នុងវិស័យតុលាការ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រះអង្គទ្រង់បានទទួលសហការ ជាមួយអំណាចនិតិបញ្ញត្តិ និតិ-ប្រតិបត្តិ និងតុលាការ។ ប្រសិនបើព្រះអង្គ មិនយល់ស្រប លើសេចក្តីសំរេចណាមួយ ព្រះអង្គទ្រង់នឹងមិនប្រថាប់ព្រះហស្ថលេខា លើសេចក្តីសំរេចនោះ ដោយស្របតាមច្បាប់។

ផ្ទុយទៅវិញ ក្នុងវិស័យដទៃទៀត ដូចជាវិស័យសេដ្ឋកិច្ច សិក្សាធិការ ឬសង្គមកិច្ច ជាដើម ដែលរដ្ឋធម្មនុញ្ញពុំបានថ្វាយអំណាច ដល់ព្រះមហាក្សត្រ ព្រះអង្គទ្រង់ត្រូវតែយល់ព្រម ឡាយព្រះហស្ថលេខាលើសេចក្តីសំរេចទាំងឡាយណា ដែលរាជរដ្ឋាភិបាល បានថ្វាយ សូមព្រះហស្ថលេខារបស់ព្រះអង្គ។

ក្នុងន័យនេះ សភាទាំង២ រួមជាមួយរាជរដ្ឋាភិបាល ត្រូវតែចាត់រៀបចំ បទបញ្ញត្តិផ្សេងៗ តាមផ្លូវច្បាប់ ឬ លិខិតបទដ្ឋាន ធ្វើយ៉ាងណា ឲ្យព្រះមហាក្សត្រ ទ្រង់អាចប្រើអំណាចធម្មនុញ្ញ របស់ព្រះអង្គ ឲ្យបានពេញលេញ និងដោយសេរី។ តែបទបញ្ញត្តិ និតិវិធីណា ដែលសំដៅ បន្ថយអំណាចផ្ទាល់ របស់ព្រះមហាក្សត្រ ដូចជាអំណាចអាជ្ញាកណ្តាល និងសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ត្រូវចាត់ទុកថាផ្ទុយនឹងរដ្ឋធម្មនុញ្ញ។

ការអះអាងថា ព្រះមហាក្សត្រកម្ពុជា ទ្រង់ពុំមានអំណាចធម្មនុញ្ញអ្វីឡើយនោះ គឺជាបទល្មើសឧក្រិដ្ឋមួយ។ អ្នករៀបរៀងច្បាប់ធម្មនុញ្ញយើង មិនអាចបញ្ញត្តិ ឲ្យព្រះមហាក្សត្រ ទ្រង់ជាអ្នកធានា ឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រយើង ទ្រង់ជាអ្នកធានា ការគោរពសន្ធិសញ្ញាអន្តរ-ជាតិ ទ្រង់ជាអ្នកធានា ការគោរពសិទ្ធិនិងសេរីភាព របស់ប្រជាពលរដ្ឋ ដោយមិនបានថ្វាយអំណាច ជាការចាំបាច់ ដល់ព្រះអង្គ ដើម្បីព្រះអង្គ ទ្រង់អាចបំពេញតួនាទីដ៏ខ្ពង់ខ្ពស់ របស់ព្រះអង្គបាន នោះឡើយ។

ប្រសិនជាអ្នករៀបរៀងរដ្ឋធម្មនុញ្ញយើង គ្មានបំណងថ្វាយអំណាចធម្មនុញ្ញ ចំពោះព្រះមហាក្សត្រទេនោះ គេមិនចាប់អារម្មណ៍ នូវការចាំបាច់ តាក់តែងមាត្រាទាំងឡាយ ដែលបានរៀបរាប់ខាងលើ ដែលថ្វាយអំណាច ចំពោះព្រះអង្គនោះឡើយ។ ការតាក់តែងមាត្រាទី៧ តែឯងនោះ វាគ្រប់គ្រាន់ណាស់ទៅហើយ ដើម្បីអះអាងថា ព្រះមហាក្សត្រគ្មានអំណាចអ្វីនោះទេ។ តែនៅក្នុងករណីយើងនេះ វាផ្សេងទៅវិញទេ។

---------------------------------------------

*(១) មាត្រាទី៥ នៃរដ្ឋធម្មនុញ្ញបារាំង ចុះថ្ងៃទី៤ តុលា១៩៥៨ ចែងថា (តាមការបកប្រែក្រៅផ្លូវការ)៖*
"ប្រធានាធិបតី នៃសាធារណរដ្ឋ ត្រៀមខ្លួនរំពៃតាមមើល ការគោរពរដ្ឋធម្មនុញ្ញ។ ក្នុងឋានៈលោក ជាអាជ្ញា-កណ្តាល លោករ៉ាប់រងធានា ការប្រព្រឹត្តិទៅ នៃអំណាចសាធារណៈ ឲ្យបានទៀងទាត់ និងនីរន្តភាពនៃរដ្ឋ។ លោកជាអ្នកធានា ឯករាជ្យជាតិ បូរណភាពទឹកដី និងការគោរពសន្ធិសញ្ញា ទាំងឡាយ"។

---------------------------------------------------------------------------------------------------------------

ធ្វើនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១